ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងអប់រំ យុវជន និងកីឡា
លេខៈ ៦៦១ អយក.ប្រក

# ប្រកាស
## ស្តីពី
## នីតិវិធី និងការរៀបចំនិងការប្រព្រឹត្តទៅរបស់
## គណៈកម្មការជ្រើសរើសអាហារូបករណ៍

## រដ្ឋមន្ត្រីក្រសួងអប់រំ យុវជន និងកីឡា

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/០៩៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០១ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញព្រះរាជក្រមលេខ នស/រកម/១២០៧/០៣២ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០០៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការអប់រំ
- បានឃើញអនុក្រឹត្យលេខ ៨៤ អនក្រ.បក ចុះថ្ងៃទី០៩ ខែមិថុនា ឆ្នាំ២០០៩ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងអប់រំ យុវជន និងកីឡា
- បានឃើញអនុក្រឹត្យលេខ ១៧៤ អនក្រ.បក ចុះថ្ងៃទី០៥ ខែឧសភា ឆ្នាំ២០១៤ ស្តីពីអាហារូបករណ៍ និងរបបឧបត្ថម្ភជីវភាពអន្តេវាសិកសម្រាប់សិស្ស និស្សិតសិក្សាតាមគ្រឹះស្ថានសិក្សាសាធារណៈ

## សម្រេច

## ជំពូកទី១
## បទប្បញ្ញត្តិទូទៅ

**ប្រការ១ .-**

ប្រកាសនេះមានគោលបំណងកំណត់អំពីនីតិវិធី និងការរៀបចំនិងការប្រព្រឹត្តទៅរបស់គណៈកម្មការជ្រើសរើសអាហារូបករណ៍សម្រាប់សិស្ស និស្សិតសិក្សានៅតាមគ្រឹះស្ថានសិក្សាសាធារណៈ។



អាសយដ្ឋានលេខ៨០ មហាវិថី ព្រះនរោត្តម ភ្នំពេញ កម្ពុជា ទូរស័ព្ទ: (៨៥៥-២៣) ២១០ ១៨៧ /២១៧ ២៥៣ /៤២៦ ៩៥១ ទូរសារ: (៨៥៥-២៣) ២១៧ ២៥០/ ២១២ ៥១២
អ៊ីមែល: info@moeys.gov.kh / crsmeys@camnet.com.kh គេហទំព័រ : www.moeys.gov.kh

**ប្រការ២ ._**

ប្រកាសនេះមានគោលដៅ៖

- រៀបចំគណៈកម្មការជ្រើសរើសអាហារូបករណ៍តាមគ្រឹះស្ថានសិក្សាសាធារណៈ
- កំណត់នីតិវិធីនិងរបៀបរបបការងាររបស់គណៈកម្មការជ្រើសរើសអាហារូបករណ៍
- កំណត់ឈ្មោះសិស្សនិងនិស្សិតដែលត្រូវបានទទួលអាហារូបករណ៍
- ធានាសុក្រឹតភាព ប្រសិទ្ធភាព និងតម្លាភាពក្នុងការជ្រើសរើស និងការផ្តល់អាហារូបករណ៍។

**ប្រការ៣ ._**

ប្រកាសនេះមានវិសាលភាពអនុវត្តចំពោះគណៈកម្មការជ្រើសរើសអាហារូបករណ៍ក្នុងការពិនិត្យ វាយតម្លៃផ្តល់អាទិភាពដល់សិស្ស និងនិស្សិតដែលត្រូវបានទទួលអាហារូបករណ៍។

## ជំពូកទី២

## សមាសភាព

**ប្រការ៤ ._**

គណៈកម្មការជ្រើសរើសអាហារូបករណ៍សម្រាប់និស្សិតសិក្សាតាមគ្រឹះស្ថានឧត្តមសិក្សាសាធារណៈ មានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| - សាកលវិទ្យាធិការ ឬនាយក ឬនាយិកា | | ប្រធាន |
| - សាកលវិទ្យាធិការរង ឬនាយករង ឬនាយិការងផ្នែកសិក្សា | | អនុប្រធានប្រចាំការ |
| - ព្រឹទ្ធបុរសមហាវិទ្យាល័យ | | សមាជិក |
| - ប្រធានការិយាល័យសិក្សា | | សមាជិក |
| - ប្រធានការិយាល័យគណនេយ្យ | | សមាជិក |
| - តំណាងគ្រូបង្រៀន | ០១រូប | សមាជិក |
| - ប្រធានសមាគមនិស្សិត ឬតំណាង | ០១រូប | សមាជិក ។ |

សមាសភាពជាក់ស្តែងនៃគណៈកម្មការនេះត្រូវជ្រើសតាំងដោយសាកលវិទ្យាធិការ ឬនាយកគ្រឹះស្ថានឧត្តមសិក្សា និងដោយមានការឯកភាពពីក្រុមប្រឹក្សាភិបាល។

**ប្រការ៥ ._**

គណៈកម្មការជ្រើសរើសអាហារូបករណ៍សម្រាប់សិស្សសិក្សាតាមគ្រឹះស្ថានមធ្យមសិក្សាឯកទេសសាធារណៈនិងគ្រឹះស្ថានបឋមសិក្សាឯកទេសសាធារណៈមានសមាសភាពដូចខាងក្រោម៖

| | | |
|---|---|---|
| - នាយក ឬនាយិកា | | ប្រធាន |
| - តំណាងមន្ទីរអប់រំ យុវជន និងកីឡា | ០១រូប | អនុប្រធាន |
| - នាយករង ឬនាយិការងផ្នែករដ្ឋបាល | | អនុប្រធាន |

- នាយករង ឬនាយិការងផ្នែកសិក្សា អនុប្រធានប្រចាំការ
- ប្រធានក្រុមបច្ចេកទេស ០៣រូប សមាជិក
- គណនេយ្យករ សមាជិក
- តំណាងគ្រូបង្រៀន ០១រូប សមាជិក ។

សមាសភាពជាក់ស្តែងនៃគណៈកម្មការនេះ ត្រូវតែងតាំងដោយនាយក ឬនាយិកាគ្រឹះស្ថានមធ្យមសិក្សាឯកទេសឬបឋមសិក្សាឯកទេស លើកលែងតែតំណាងមន្ទីរអប់រំ យុវជន និងកីឡាដែលត្រូវស្នើសុំសមាសភាពពីមន្ទីរអប់រំ យុវជន និងកីឡា។

**ប្រការ៦ .-**

សមាសភាពគណៈកម្មការជ្រើសរើសអាហារូបករណ៍សម្រាប់សិស្ស និស្សិតសិក្សាតាមគ្រឹះស្ថានសិក្សាសាធារណៈត្រូវរៀបចំឡើងវិញរៀងរាល់២(ពីរ)ឆ្នាំម្តង។

## ជំពូកទី៣
## ភារកិច្ច

**ប្រការ៧ .-**

គណៈកម្មការជ្រើសរើសអាហារូបករណ៍មានភារកិច្ចដូចតទៅះ

- រៀបចំផែនការការងារនិងផែនការចំណូល ចំណាយក្នុងការផ្តល់អាហារូបករណ៍
- ផ្សព្វផ្សាយព័ត៌មានស្តីពីការផ្តល់និងការទទួលអាហារូបករណ៍
- រៀបចំគំរូពាក្យស្នើសុំអាហារូបករណ៍និងបែបបទពាក់ព័ន្ធផ្សេងទៀត
- ទទួលពាក្យស្នើសុំអាហារូបករណ៍
- ចូលរួមប្រជុំវាយតម្លៃសំណុំឯកសារស្នើសុំអាហារូបករណ៍តាមការអញ្ជើញរបស់ប្រធាន
- ចុះពិនិត្យដល់មូលដ្ឋានរបស់សិស្ស និស្សិតដែលត្រូវទទួលអាហារូបករណ៍ក្នុងករណីចាំបាច់
- ធ្វើរបាយការណ៍ជូនថ្នាក់ដឹកនាំតាមឋានានុក្រមអំពីលទ្ធផលនៃការជ្រើសរើស ការផ្តល់និងការទទួលអាហារូបករណ៍
- ដោះស្រាយរាល់បាតុភាពនានាដែលពាក់ព័ន្ធនឹងអាហារូបករណ៍
- ទទួលបន្ទុកអនុវត្តភារកិច្ចផ្សេងទៀតដែលថ្នាក់ដឹកនាំប្រគល់ជូន។

## ជំពូកទី៤
## របៀបរបបការងារ

**ប្រការ៨ .-**

គណៈកម្មការជ្រើសរើសអាហារូបករណ៍ត្រូវដំណើរការប្រជុំសម្រេចផ្តល់អាហារូបករណ៍ក្រោមការដឹកនាំរបស់ប្រធាន។



រិ៍៩

ការប្រជុំសម្រេចក្នុងការផ្តល់អាហារូបករណ៍អាចប្រព្រឹត្តទៅបានលុះត្រាមានសមាសភាពចូលរួមយ៉ាងតិចពីរភាគបីនៃចំនួនសមាជិកសរុប។

រាល់ការសម្រេចក្នុងអង្គប្រជុំត្រូវកំណត់យកជាការបានលុះត្រាតែមានសំឡេងគាំទ្រយ៉ាងតិចហាសិបភាគរយបូកមួយ(៥០%+១)នៃសមាជិកដែលបានចូលរួមប្រជុំ និងមានការឯកភាពពីក្រុមប្រឹក្សាភិបាល។ ក្នុងករណីសំឡេងស្មើគ្នា សំឡេងរបស់ប្រធានមានឧត្តមានុភាពក្នុងការសម្រេច។

## ជំពូកទី៥

## អវសានប្បញ្ញត្តិ

**ប្រការ៩ ._**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ១០ ._**

អគ្គនាយកនៃអគ្គនាយកដ្ឋានឧត្តមសិក្សា អគ្គនាយកនៃអគ្គនាយកដ្ឋានអប់រំ អគ្គនាយកនៃអគ្គនាយកដ្ឋានរដ្ឋបាល និងហិរញ្ញវត្ថុ អគ្គនាយកនៃអគ្គនាយកដ្ឋានយុវជន អគ្គនាយកនៃអគ្គនាយកដ្ឋានកីឡា អគ្គាធិការនៃអគ្គាធិការដ្ឋាន ប្រធាននាយកដ្ឋានឧត្តមសិក្សា ប្រធាននាយកដ្ឋានស្រាវជ្រាវវិទ្យាសាស្ត្រ ប្រធាននាយកដ្ឋានតម្រង់ទិសវិជ្ជាជីវៈ ប្រធាននាយកដ្ឋានហិរញ្ញវត្ថុ សាកលវិទ្យាធិការនៃសាកលវិទ្យាល័យសាធារណៈ នាយកវិទ្យាស្ថានសាធារណៈក្រោមឱវាទក្រសួងអប់រំ យុវជន និងកីឡា និងប្រធានគ្រប់អង្គភាពពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ២០១៤

បណ្ឌិត ហង់ ជួន ណារ៉ុន

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ខុទ្ទកាល័យក្រសួង អ.យ.ក.
- គ្រប់នាយកដ្ឋានក្រោមឱវាទក្រសួង អ.យ.ក.

  "ដើម្បីជូនជ្រាប"
- គ្រប់មន្ទីរអប់រំ យុវជន និងកីឡារាជធានី ខេត្ត
- គ្រប់គ្រឹះស្ថានឧត្តមសិក្សាសាធារណៈ
- គ្រប់គ្រឹះស្ថានមធ្យមសិក្សានិងបឋមសិក្សាឯកទេស
- ដូចប្រការ១០

  "ដើម្បីអនុវត្ត"
- ឯកសារ កាលប្បវត្តិ នា. នីតិកម្ម